សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

CAMBODIAN LEAGUE FOR THE PROMOTION AND DEFENSE OF HUMAN RIGHTS

**LICADHO**

លីកាដូ

LICADHO

# កម្មវិធីបណ្តុះបណ្តាលសិទ្ធិមនុស្សដល់សិស្សនិងនិស្សិត

# HUMAN RIGHTS EDUCATION PROGRAM FOR STUDENTS




រៀបចំដោយ

គ្រូអប់រំសិទ្ធិមនុស្សនៃអង្គការលីកាដូ

**Prepared by LICADHO's Trainers**


សំរាប់សិក្ខាកាម

**FOR PARTICIPANTS**


រក្សាសិទ្ធិ ២០០៤ ដោយអង្គការលីកាដូ

**Copyright 2004 by LICADHO**

# កម្មវិធីបណ្តុះបណ្តាលសិទ្ធិមនុស្សដល់សិស្សនិងនិស្សិត

## ១-បុព្វកថា :

យុវជន/នារីគឺជាពន្លកថ្មីក៏ដូចជាកម្លាំងដ៏ស្រស់ស្រាវបំផុតសំរាប់សង្គមជាតិ ។ នៅក្នុងចំណោមពួកអ្នកដ៏ច្រើន បានឆ្លងកាត់ការយល់ដឹងអំពីសិទ្ធិមនុស្សរួចទៅហើយ ប៉ុន្តែឥឡូវនេះគឺជាតំណាក់ការដើម្បីបង្កើតយុទ្ធសាស្ត្រសំរាប់ការពារសិទ្ធិមនុស្ស ឬក៏មានន័យថាបង្កើតយុទ្ធសាស្ត្រទប់ស្កាត់ការរំលោភសិទ្ធិមនុស្ស ដូច្នេះអ្នកគួរតែចូលរួមបន្តទៀតនៅក្នុងតំណាក់ការខាងលើនេះដើម្បីធ្វើឱ្យមានសកម្មភាពកែប្រែអ្វីមួយនៅក្នុងសង្គម ព្រោះថាអំពើរំលោភសិទ្ធិមនុស្សនានាគ្រប់ប្រភេទកំពុងនៅតែរីករាលដាលធ្ងន់ធ្ងរនៅឡើយមកលើរូបអ្នក។

## ២-គោលបំណង

សង្ឃឹមថា :

1-សិស្សនិងនិស្សិតនឹងយល់ស្របអំពីអ្វីដែលជាសំណូមពរនៅក្នុងការពិភាក្សានេះ ដើម្បីរៀបចំបង្កើតយុទ្ធសាស្ត្រសំរាប់ការពារសិទ្ធិមនុស្ស ។

2-សិស្សនិងនិស្សិតប្រាកដជាពេញចិត្តនឹងបង្កើតជា " ក្រុមសហការ ឬជាបណ្តាញការងារ " ដែលជាយុទ្ធសាស្ត្រចម្បង សំរាប់ការជួយសហការចូលរួមដោះស្រាយបញ្ហាអ្វីមួយតាមរយៈក្រុម ឬបណ្តាញ និងទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

## ៣-វិធីដំណើរការវគ្គ

កម្មវិធីនៃវគ្គសិក្សានេះទាំងមូល គឺជារបៀបពិភាក្សាផ្តល់យោបល់គ្នាទៅវិញទៅមកក្នុងការបង្កើតយុទ្ធសាស្ត្រសំរាប់ការពារសិទ្ធិមនុស្សនៅក្នុងមូលដ្ឋាន ។ ដូច្នេះបានន័យថាវគ្គនេះគឺផ្តល់ឱកាសឱ្យអ្នកទាំងអស់ចូលរួមផ្តល់យោបល់ទៅលើករណីសិក្សាជាច្រើនថាតើគួររកដំណោះស្រាយបែបណាដើម្បីជួយកាត់បន្ថយការរំលោភសិទ្ធិមនុស្សទាំងឡាយឱ្យមានប្រសិទ្ធិភាព

* វគ្គបណ្តុះបណ្តាលនេះមានរយៈពេលបីថ្ងៃនិងរំពឹងទុកថា អ្នកទាំងអស់នឹងបញ្ចេញគំនិតយ៉ាងផុលផុសនិងពេញទំហឹង ដើម្បីរកឱ្យឃើញនូវយុទ្ធសាស្ត្រសំរាប់ការពារ ។
* វគ្គបណ្តុះបណ្តាលនេះ អ្នកសំរបសំរួលវគ្គនឹងមានរៀបចំល្បែងស្ពានគំនិតយ៉ាងហោចណាស់ក្នុងមួយថ្ងៃឱ្យបានមួយល្បែង។
* នៅចុងបញ្ចប់នៃវគ្គ សិក្ខាកាមនឹងត្រូវបានស្នើសុំឱ្យធ្វើការវាយតម្លៃទៅលើលទ្ធផលទូទៅរបស់វគ្គទាំងមូល ។
* បន្ទាប់ពីវគ្គនេះទៅនឹងមានវគ្គបន្ត (Follow-up) មានរយៈពេលមួយថ្ងៃ ចំពោះកាលបរិច្ឆេទនឹងជូនដំណឹងនៅពេលក្រោយ ។

# មាតិកា


| លេខរៀង | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១ | **★សីលធម៌និងសិទ្ធិមនុស្ស**<br>-ទស្សនៈនៃអត្ថបទ<br>-សំនួរពិភាក្សា | ១-៤ |
| ២ | **★ការកសាងសង្គមស៊ីវិល**<br>-ទស្សនៈនៃអត្ថបទ<br>-សំនួរពិភាក្សា | ៥-៨ |
| ៣ | **★សេរីភាពនៃការបញ្ចេញមតិនិងការចូលរួម/វិធីទាក់ទាញការគាំទ្រ**<br>-ទស្សនៈនៃអត្ថបទ<br>-សំណួរពិភាក្សា | ៩-១៣ |
| ៤ | **★លុបបំបាត់ការរើសអើងចំពោះស្ត្រី/ទស្សនៈយេនឌ័រ** (Gender)<br>-ទស្សនៈនៃអត្ថបទ<br>-សំណួរពិភាក្សា | ១៤-១៩ |
| ៥ | **★សិទ្ធិអប្បភាគជន/ជនជាតិភាគតិច**<br>-ទស្សនៈនៃអត្ថបទ<br>-សំនួរពិភាក្សា | ២០-២៤ |
| ៦ | **★ការបង្កើតយុទ្ធសាស្ត្រសំរាប់ការពារ**<br>-ទស្សនៈនៃអត្ថបទ<br>-សំនួរពិភាក្សា | ២៥-២៩ |

# សីលធម៌ និង សិទ្ធិមនុស្ស

**I.ទស្សនៈ** មនុស្សមិនអាចធ្វើអ្វីតាមតែអំពើចិត្តរបស់ខ្លួននោះឡើយ ដោយយកលេសថាខ្លួនមានសិទ្ធិ ការយល់ឃើញដូច្នេះគឺជាការផ្តុយស្រលះ ។

ផ្នែកមួយនៃសិទ្ធិមនុស្ស បានបង្កប់និងសង្កត់ធ្ងន់យ៉ាងជ្រាលជ្រៅអំពីសីលធមិ គុណធមិ ក៏ដូចជាសុជីវធមិផងដែរ ដែលបានចែងយ៉ាងច្បាស់នៅក្នុងក្រមសិទ្ធិមនុស្សអន្តរជាតិ ។



សិទ្ធិមនុស្សផ្នែកសីលធមិមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងបរិបទសង្គម ឬទំនៀមទម្លាប់ដ៏ល្អរបស់សង្គម មានន័យយ៉ាងសាមញ្ញថា ការចេះគោរពគ្នាទៅវិញទៅមក ការស្គាល់អ្វីថាគួរ អ្វីមិនគួរ អ្វីល្អ អ្វីអាក្រក់ អ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ ឬក៏មានន័យថា " សិទ្ធិនិងការទទួលខុសត្រូវ " ដោយចេះលៃលកយ៉ាងណាកុំឱ្យប៉ះពាល់សិទ្ធិអ្នកដទៃ នាំឱ្យគេមានការក្តៅក្រហាយ ដែលនឹងនាំមកនូវទុក្ខទោសដល់ខ្លួន ដល់សង្គមគ្រួសារ មិនអាចជៀសវាងបានឡើយ ។

ការបាត់បង់នូវសីលធមិ សុជីវធមិ និងគុណធម៌ វាជាការបោះជំហានទៅរកការប្រព្រឹត្តអំពើខុសច្បាប់ ដែលបច្ចុប្បន្ននេះគេសង្កេតឃើញយុវជនខ្មែរទាំងក្រៅសាលា ទាំងក្នុងសាលា បាននិងកំពុងធ្វើឱ្យសីលធមិ សុជីវធមិខ្មែរ ដែលធ្លាប់មានពីអតីតកាលស្រុតចុះយ៉ាងខ្លាំង ហើយដែលទង្វើនេះនឹងធ្វើឱ្យប៉ះពាល់ដល់សន្តិភាពជាតិ ដល់ការអភិវឌ្ឍន៍ជាតិ ជាពិសេសនាំឱ្យអន្តរាយដល់ខ្លួនឯងថែមទៀតផង ។ ដូច្នេះយុវជន យុវនារីត្រូវតែគិតគូរសាឡើងវិញដោយជ្រើសយកប្រពៃណី/ទំនៀមទម្លាប់ខ្មែរដ៏ល្អបំផុតមានឱវាទចាស់ទុំជាច្រើនតំណ និងប្រពៃណីព្រះពុទ្ធសាសនាដែលបានអប់រំកុលបុត្រខ្មែរជាយូរលង់ណាស់មកហើយឬសីលធមិដែលល្អរបស់អារ្យប្រទេស មកធ្វើការគោរពនិងអនុវត្ត ដើម្បីជាកិត្តិយសដល់ឪពុកម្តាយ/អណាព្យាបាល ដល់សង្គមជាតិ និង ជាពិសេសសំរាប់អនាគតរបស់ខ្លួនឯងដ៏ល្អគួរជាទីរាប់អាន ។

* **សំនួរ**

1-តើអ្វីខ្លះជាគំនិតសំខាន់ៗនៅក្នុងទស្សនៈនេះ ?

2-តើមានបញ្ហាអ្វីខ្លះ ដែលជាទង្វើប្រាសចាកពីសីលធម៌/សុជីវធម៌ ធ្វើឱ្យប៉ះពាល់សិទ្ធិមនុស្សនិងច្បាប់សព្វថ្ងៃនេះ របស់យុវជន/នារីយើង ?



* **សំដែងតួ**

យុវជនពីរនាក់ សួសនិង សេន អង្គុយទល់មុខគ្នាកំពុងតែផឹកស៊ីស្រវឹងឡើងទោរ សួសបានសួរទៅសេនថា យប់នេះមានរាំទេរឺយ ?

**សេន** :ឆ្លើយថា ប្រាកដជាមានអាម៉ាក!

**សួស** : សប្បាយទៀតហើយយើង! អាណាហ៊ានអួងអាត់ ***(រូបភាពកុមារកំពុងហឺតថ្នាំញៀន)***

ត្រូវវៃ!វៃ ត្រូវកាប់កាប់! យប់នេះ កុំទៅគិតអារឿងរៀនសូត្រគង់តែចេះទេ បោកម៉ែឪយើងថារៀនគួរថែមទៅ លុយចេះតែធ្លាក់មំខ្លាកៗហើយ ។

**សេន** : (ដោយកាយវិការភ្ញាក់ព្រើត) ប្រាប់ទៅសួសថា បានឡើងស្ពានសួគ៌ហើយយើងឯងមើលអាវ៉ា (នារី) ដើរមករកយើងហើយណាក់ ។

**សួស-សេនៈ** (និយាយព្រមគ្នា) ចាប់កុំលែងវេះ ស្រលាញ់បងទេអូនស្រី ដៃអូនក៏ត្រជាក់ម្ល៉េះ? ពេលនោះឪពុកនាងមកទាន់ ហើយគាត់ក៏បានប្ដឹងទៅប៉ូលីសភ្លាម ។

* **សំនួរ -ចម្លើយជារួម**

១-តើយុវជនទាំងពីរនេះបានប្រព្រឹត្តអំពើអ្វីខ្លះ ?

២-តើយុវជនទាំងពីរ ទទួលបានផលល្អអ្វីខ្លះ ?

៣-តើយុវជនទាំងពីរទទួលនូវផលវិបាកដូចម្ដេចខ្លះ ? អ្នកណាខ្លះដែលទទួលខុសត្រូវក្នុងរឿងនេះដែរ ?

**ពិភាក្សាតាមក្រុម** :

1-ដើរតួពីការសំពះចាស់ទុំ ចូរពន្យល់តើការសំពះសួរមានប្រយោជន៍ឬទេ ? មានប្រយោជន៍ដូចម្តេចខ្លះ ? ប្រយោជន៍ត្រង់ណាដែលជាអាទិភាពជាងគេបំផុតនៃការសំពះ ?

2-រូបភាពកុមារ/យុវជនញៀនថ្នាំ ចូរពន្យល់ហេតុដែលបណ្តាលឱ្យកុមារ/យុវជនញៀនថ្នាំ ?

3-មានវិធីអ្វីខ្លះ ដើម្បីការពារខ្លួនអ្នកកុំឱ្យធ្លាក់ទៅក្នុងការញៀនថ្នាំ ?

1-ហេតុដែលបណ្តាលឱ្យយុវជននេះកើតជម្ងឺអេដស៍ ?

2-វិធីអ្វីខ្លះ ដែលមានប្រសិទ្ធិភាពសំរាប់ការពារខ្លួនអ្នក ?

**★ សំនួរបញ្ចប់ជារួម**

តើត្រូវមានទម្លាប់និងប្រព្រឹត្តដូចម្តេចខ្លះ ដើម្បីក្លាយជាយុវជន/នារីល្អ ?

## VI.អត្ថបទជំនួយ

### ១-សិទ្ធិមនុស្សនិងការទទួលខុសត្រូវ

ការប្រើប្រាស់សិទ្ធិរបស់មនុស្សម្នាក់ៗ ត្រូវឱ្យមានតុល្យភាពទៅនឹងការទទួលខុសត្រូវ មានន័យថា បើយើងចង់ឱ្យមានសុវត្ថិភាពខ្លួនយើង យើងត្រូវតែចេះគោរពសុវត្ថិភាពរបស់អ្នកដទៃ ។

ឧ.បើយុវជនណាម្នាក់ធ្វើឱ្យប៉ះពាល់ឬបៀតបៀនកេរ្តិ៍ខ្មាសដល់ស្ត្រីភេទ ត្រូវបានទទួលខុសត្រូវដោយការចាប់ខ្លួនតាមរយៈប៉ូលីសនិងតុលាការឯករាជ្យ ។



(រូបភាព***កុមារកំពុងញៀនថ្នាំ*** )

ឧ.បើយុវជនណាម្នាក់ជក់គ្រឿងញៀនត្រូវបានទទួលខុសត្រូវដូចគ្នានឹងករណីខាងលើដែរ ។

**ក**/យោងតាមមាត្រា២៩នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ដែលនិយាយអំពីកាតព្វកិច្ចចំពោះសហគមន៍និងគោរពសិទ្ធិអ្នកដទៃ បានចែងថា : បុគ្គលគ្រប់រូបមានភារកិច្ចចំពោះសហគមន៍ដែលខ្លួនរស់នៅ។

ការប្រើប្រាសសិទ្ធិរបស់មនុស្សម្នាក់ៗ ត្រូវមានព្រំដែនច្បាស់លាស់ ដើម្បីកុំឱ្យមានការ

ប៉ះពាល់ដល់សិទ្ធិនិងសេរីភាពអ្នកដទៃ ។ សិទ្ធិនិងសេរីភាពទាំងនោះមិនអាចយកទៅប្រើប្រាស់ផ្ទុយពីគោលបំណងនិងគោលការណ៍អង្គការសហប្រជាជាតិបានឡើយ ។

**ខ**/យោងតាមរដ្ឋធម្មនុញ្ញមាត្រា៣១ (កថាខណ្ឌ៣) បានចែងថា :

ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះត្រូវតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

## ២-សីលធម៌ប្រពៃណី

មធ្យោបាយមួយដែលអាចធ្វើឱ្យយុវជន/នារីយើងក្លាយជាពលរដ្ឋល្អ គឺខិតខំយ៉ាងណាធ្វើឱ្យរស់ឡើងវិញនូវសីលធម៌ប្រពៃណីរបស់ដូនតាដែលមាននៅក្នុងគ្រួសារ វត្តអារ៉ាម ឬតាមភូមិស្ថាន ប្រពៃណីទាំងនោះមានដូចជា ការចេះគោរពចាស់ទុំ ចេះមានការយោគយល់-អធ្យាស្រ័យគ្នា ការចេះប្រមាណ ការចេះគួរសម កិរិយាមារយាទរម្យទម ជាពិសេសសីលធម៌របស់ព្រះពុទ្ធសាសនា ឬហៅថា សីលប្រាំ ដែលជាក្បួនអប់រំចិត្តយ៉ាងសំខាន់ មានដូចជា :

| | |
|---|---|
| 1-បាណាតិបាតា... | ហាមសម្លាប់ |
| 2-អទិន្នាទានា... | ហាមលួច-ប្លន់ |
| 3-កាមេសុមិច្ឆា.. | ហាមប៉ះពាល់/រំលោភ កូន-ប្រពន្ធ-ប្ដីគេ ផ្នែកកាម |
| 4-មុសា... | ហាមកុហក បោកបញ្ឆោត ញុះញង់និងនិយាយដើមគេ |
| 5-សុរាមេរយ... | ហាមថ្នាំញៀន និងគ្រឿងស្រវឹង |

(បើរក្សាសីលប្រាំនេះបាននឹងក្លាយជាពលរដ្ឋល្អ)

៚ **ចប់** ៚

# ការកសាងសង្គមស៊ីវិល

**I. ទស្សនៈ** : នៅក្នុងប្រទេសកម្ពុជា ការចាប់ផ្តើមធ្វើឱ្យមានចលនានៃសង្គមស៊ីវិលបានរីកសុស




*(ការចូលរួមពិភាក្សាសិទ្ធិមនុស្សពីកងកម្លាំងនគរបាលនិងប្រជាពលរដ្ឋ)*

សាយយ៉ាងខ្លាំងក្លាចាប់តាំងពីឆ្នាំ១៩៩២មក ។ ពលរដ្ឋកម្ពុជាបានចូលរួមយ៉ាងកុះករ ដោយហេតុថា ពួកគេធ្លាប់បានទទួលការពិសោធន៍ស្តីពីការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនៅក្នុង២-៣ទសវត្សមុននេះ ។ អង្គការក្រៅរដ្ឋាភិបាលនានា បាននិងកំពុងធ្វើវិភាគទានយ៉ាងសកម្មចំពោះការអភិវឌ្ឍន៍សង្គមស៊ីវិលព្រោះថាសង្គមនេះជាអង្គធាតុដ៏សំខាន់នៃលទ្ធិប្រជាធិបតេយ្យ ។

ការកសាងសង្គមស៊ីវិលមានន័យថា ធ្វើឱ្យមនុស្សទាំងអស់ចេះដឹង និងអាចធ្វើការទៅតាមសេចក្តីប្រាថ្នាឬជាសិទ្ធិរបស់ខ្លួនខាងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ជាពិសេស ខាងស្មារតី



ដើម្បីជួយជំរុញសង្គមជាតិទាំងមូលឱ្យមានការគ្រប់គ្រងដោយច្បាប់ ជាពិសេសគឺផ្តោតទៅលើការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន ។ ចំពោះរឿងនេះអង្គការក្រៅរដ្ឋាភិបាលនានាអាចជួយដល់ការរៀបចំបែបនេះ ក្រុមទាំងនេះមិនស្វែងរកប្រជាប្រិយដើម្បីអំណាច ដូចគណបក្សនយោបាយឡើយក៏ប៉ុន្តែក្រុមទាំងនេះកំពុងដើរតួជាភ្នាក់ងាររបស់សង្គមស៊ីវិលដោយមិនទ្រេតទៅរកសង្គមនយោបាយណាមួយ ហើយពួកគេពិតជាបាននិងកំពុងយកចិត្តទុកដាក់ពីបញ្ហាមួយចំនួនធំក្នុង

សង្គមជាតិ ដូចជាក្រុមខ្លះមានការបណ្ដុះបណ្ដាលក្នុងការជួយលើកស្ទួយនិងការពារសិទ្ធិមនុស្ស-ច្បាប់ នៅពេលគេរំលោភ និង ក្រុមខ្លះទៀតកំពុងរួមចំណែកអភិវឌ្ឍន៍ជនបទក្រខ្សត់ ដូចជា កសាងលំនៅដ្ឋាន ជំនួយផ្នែកសុខភាព សិក្សាអប់រំ ពលកម្ម បរិស្ថាន និងការកែទម្រង់ដីធ្លី ។ល។



សរុបសេចក្ដីមកដើម្បីកសាងសង្គមស៊ីវិលបាន គឺមិនមែនមានតែស្ថាប័នណាមួយទោលតែឯងនោះទេ លុះត្រាតែមានការចូលរួមពីអ្នកទាំងអស់គ្នា ឬពីភ្នាក់ងារដទៃច្រើនទៀត ទើបការអភិវឌ្ឍន៍ជាតិអាចជឿនលឿនទៅបាន ។

•**សំនួរ** :

1-អ្នកធ្លាប់ស្គាល់អង្គការសង្គមស៊ីវិលណាខ្លះ ? ហេតុអ្វីបានជាស្គាល់ ?

2-តើអ្វីខ្លះជាគំនិតសំខាន់នៅក្នុងទស្សនៈនេះ ?

★**ពិភាក្សាសំនួរ**

1-ហេតុអ្វីបានជាមានចលនាសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា ?

2-តើអ្នកដឹងថាអង្គការសង្គមស៊ីវិលធ្វើការទៅលើវិស័យអ្វីខ្លះ ? សូមផ្ដល់យោបល់ដោយលើកឧទាហរណ៍ អង្គការឬសមាគម ដែលអ្នកធ្លាប់ស្គាល់ ?

3-តើអង្គការសង្គមស៊ីវិលមានប្រយោជន៍ឬទេ ? មានប្រយោជន៍អ្វីខ្លះ ?

4-ទស្សនៈខ្លះយល់ថា មានតែរដ្ឋាភិបាលតែមួយគត់ដែលជាអ្នកអភិវឌ្ឍន៍ប្រទេស តើអ្នកយល់យ៉ាងដូចម្ដេចដែរចំពោះយោបល់នេះ ហេតុអ្វី ?

5-តើការកសាងសង្គមស៊ីវិលដើម្បីអ្វី ?

6-តើអ្នកមានការភ័យខ្លាច ឬក៏គិតថាខុសច្បាប់ចំពោះការចូលរួមរបស់អ្នកជាមួយអង្គការសង្គមស៊ីវិល? សូមផ្ដល់យោបល់ ?

7-តើអ្នកគិតថាអង្គការសង្គមស៊ីវិល ដូចគណបក្សនយោបាយឬទេ ? ហេតុអ្វី ? តើគេមានគោលការណ៍ដូចម្ដេចខ្លះ ?

★ **សំនួរបញ្ចប់**

1-តើអ្នកបានសិក្សាអំពីអ្វីខ្លះ អំបាញ់មិញ ?

2-តើអ្នកពេញចិត្តចំពោះអង្គការសង្គមស៊ីវិលឬទេ ? ហេតុអ្វី ?

## VI.**អត្ថបទជំនួយ**

### ១-តួនាទីនិងសកម្មភាពរបស់អង្គការសង្គមស៊ីវិល

អង្គការសង្គមស៊ីវិលជាច្រើន បាននិងកំពុងធ្វើសកម្មភាព ដោយឈរលើមាតិនៃមូលដ្ឋានសិទ្ធិធំៗ ទាំង៥ មានសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ដើម្បីជួយកសាងសង្គមស៊ីវិលមួយនៅកម្ពុជា និងធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល ក្នុងការជួយអភិវឌ្ឍន៍លើគ្រប់វិស័យរបស់ប្រទេសនេះឡើងវិញ បន្ទាប់ពីសង្គ្រាមដ៏រ៉ាំរ៉ៃអស់ជាច្រើនទសវត្ស ។

កម្មវិធីរបស់អង្គការសង្គមស៊ីវិលដែលកំពុងធ្វើសកម្មភាពមានតួនាទីសំខាន់ៗដូចជា :

1-ជួយកាត់បន្ថយភាពក្រីក្រក្នុងសង្គម ជាពិសេសនៅតាមមូលដ្ឋានដាច់ស្រយាល ។

2-ចូលរួមយ៉ាងសកម្មដើម្បីលើកស្ទួយសន្តិភាព ប្រជាធិបតេយ្យ និងសិទ្ធិមនុស្សដើម្បីបង្កើនការគោរពសិទ្ធិមនុស្ស និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ។

3-សង្កេតមើលការបោះឆ្នោតដើម្បីធានានូវការបោះឆ្នោតឱ្យប្រព្រឹត្តទៅដោយសេរី-ត្រឹមត្រូវ និងយុត្តិធម៌ ដែលគួរឱ្យទុកចិត្តបាន ។

4-ឃ្លាំមើលបទរំលោភសិទ្ធិមនុស្ស

5-ជួយការពារបរិស្ថាន

6-ជួយការពារក្ដីដល់ជនរងគ្រោះពីបទរំលោភសិទ្ធិមនុស្ស ។



( *អំពើហិង្សាដោយហ្វូងមនុស្ស* )

7-ជួយធ្វើឱ្យមានការកែប្រែច្បាប់តាមរយៈការបញ្ចុះបញ្ចូល ( ការតស៊ូមតិ ) ចំពោះអ្នកមានឥទ្ធិពល ។

8-ជួយរៀបចំធ្វើឱ្យមានសមភាព សមធម៌រវាងបុរសនិងស្ត្រី (Gender)

9-ជួយលើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យមានការចូលរួមក្នុងដំណើរការអភិវឌ្ឍន៍ខ្លួនឯង និងសង្គម ។

10-ជួយបង្កើនការភ្ញាក់រលឹកនិងការយល់ដឹងពីស្ថានភាពនិងដំណើរប្រព្រឹត្តទៅនៃសង្គមស៊ីវិល ។

**២-សារសំខាន់នៃអង្គការសង្គមស៊ីវិល**

អង្គការសង្គមស៊ីវិលមានសារសំខាន់ក្នុងការបំរើផលប្រយោជន៍សង្គមដូចតទៅ :

1-សេរីភាពក្នុងការបង្កើតសមាគមនិងសេរីភាពក្នុងការបញ្ចេញមតិ

2-លើកស្ទួយស្ថិរភាពសង្គមនិងធ្វើឱ្យមានការគ្រប់គ្រងដោយច្បាប់

3-លើកស្ទួយសិទ្ធិមនុស្សនិងប្រជាធិបតេយ្យពហុនិយមនិងការយល់អធ្យាស្រ័យគ្នា

4-ជួយធ្វើឱ្យមានភាពសម្បូរសប្បាយរុងរឿងក្នុងសង្គម ។ល។

**៣-រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា**

<u>មាត្រា៣៥</u> : ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

សេចក្ដីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យនិងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

<u>មាត្រា៤១</u> : ប្រជាពលរដ្ឋខ្មែរមានសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

<u>មាត្រា៤២</u> :

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ដោយច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយអាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិនិងសណ្ដាប់ធ្នាប់សង្គម ។

**ចប់**

# សេរីភាពនៃការបញ្ចេញមតិនិងការចូលរួម/ការតស៊ូមតិ

I. **ទស្សនៈ** សេរីភាពជាប្រភពនៃសិទ្ធិពលរដ្ឋនិងនយោបាយឬក៏ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ ដែលជាសេចក្ដីត្រូវការចាំបាច់បំផុតសំរាប់បុគ្គលគ្រប់រូប ដោយក្នុងនោះមានចំណុចពិសេសមួយផង ដែរ គឺការបោះឆ្នោតសម្ងាត់ ដោយសេរី សំរាប់ការជ្រើសរើសតំណាងឱ្យទៅដឹកនាំប្រទេស ។



និយាយរួម សេរីភាពគឺអ្វីដែលមនុស្សអាចធ្វើទៅបាន ដោយមិនទទួលរងនូវការដាក់កំហិត ការយាយី ការបង្ខិតបង្ខំ ការបំភិតបំភ័យ ។ល។ អ្នកអាចដឹងថា អ្នកគ្មានសេរីភាពនៅពេលដែលមនុស្សណាម្នាក់តម្រូវ/បង្ខំឱ្យធ្វើអ្វីមួយ ដោយគ្មានការសុំយោបល់ ឬចូលទៅសំរេចចាត់ចែងកិច្ចការអ្វីមួយដែលជាកិច្ចការរបស់អ្នក ឬ បង្កើតចលនាបង្ក្រាបឱ្យអ្នកខ្លាចរអា តក់ស្លុត ធ្វើឱ្យបាត់បង់នូវការតស៊ូ ការនិយាយស្ដីឬតវ៉ាជាដើម ។

ម្យ៉ាងវិញទៀត ចំពោះការយាយីក្នុងការសំដែងមតិ ដូចជាត្រូវបានគេរំខាន បំភ័យ បង្អាក់ រារាំង ដាក់កំហិត បង្ខិតបង្ខំ ឬជ្រៀតជ្រែក ទាំងអស់នេះគឺជាអំពើរំលោភសិទ្ធិមនុស្ស រំលោភប្រជាធិបតេយ្យ និងជាការរំលោភទៅលើសេរីភាពក្នុងការបញ្ចេញមតិទាំងស្រុង ។






សេរីភាពក្នុងការបញ្ចេញមតិនិងការចូលរួមគឺជាបេះដូងនៃលទ្ធិប្រជាធិបតេយ្យ សំរាប់ធ្វើឱ្យសង្គមមានតុល្យភាពក្នុងការសំរេចអ្វីមួយមានតម្លាភាព មានយុត្តិធម៌ មានការអភិវឌ្ឍន៍ដ៏ល្អប្រសើរ ។ ផ្ទុយទៅវិញ ប្រជាធិបតេយ្យវានឹងស្លាប់បើយើងមិនប្រើប្រាស់វាឱ្យសមស្រប ឬក៏ការសំរេចចិត្តណាមួយត្រូវបានគេបង្ខំ/ដាក់កំហិត គំរាម ឬត្រូវបានគេបញ្ជោរ ឬ បញ្ឆេចបញ្ឆៀ ឬទិញទឹកចិត្តដើម្បី

ផលប្រយោជន៍ណាមួយនោះ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់សេរីភាពទោះជាតាមវិធីណាក៏ដោយ ដូចជាតាមការសុំណាត់ជួបតំណាងណាមួយ ឬតាមរយៈកាសែត ទស្សនាវដ្តី ឬធ្វើកូដកម្ម ឬបាតុកម្មក្តី ត្រូវតែបានប្រព្រឹត្តឡើងដោយសន្តិវិធី ដោយអហិង្សាប្រកបទៅដោយក្រមសីលធម៌ខ្ពស់ និងមានការទទួលខុសត្រូវផងដែរ ។ ដូច្នេះយុវជន/នារីយើង ត្រូវហ៊ានប្រើប្រាស់សេរីភាពក្នុងការបញ្ចេញមតិ/ការចូលរួម ទោះជាចំហក្តី ជាសម្ងាត់ក្តី ត្រូវមានទំនុកចិត្តខ្លួនឯង ដើម្បីទាមទារនូវអ្វីមួយដែលជាបញ្ហារំលោភសិទ្ធិមនុស្ស/ច្បាប់ និងជួយធ្វើឱ្យមានស្ថានភាពកែប្រែប្រសើរឡើងនូវយុត្តិធម៌ តម្លាភាព សំរាប់កិច្ចអភិវឌ្ឍន៍ក្នុងការរស់នៅរបស់ខ្លួន និង សង្គមជាតិទាំងមូលឱ្យកាន់តែមានការរីកចំរើន ។

**★ តើអ្វីខ្លះជាគំនិតសំខាន់ៗនៅក្នុងទស្សនៈនេះ ?**

**★សំនួរ**

១-តើអ្វីខ្លះចាត់ទុកជាសេរីភាពក្នុងការសំដែងមតិ/ការចូលរួម ?

២-តើកន្លងមកការសំដែងមតិ/ការចូលរួមអ្វីខ្លះត្រូវបានគេបង្ខាក់ បំភ័យ រំខាន រារាំង ?

៣-តើមានអ្នកត្រូវបានគេធ្វើទុក្ខទោស សម្លាប់ ដោយសារការសំដែងមតិ/ការចូលរួម ទាំងនេះទេ ?

៤-តើកន្លងមក ការសំដែងមតិណាមួយរបស់អ្នកត្រូវបានគេ បំភ័យ បង្ខាក់ រំខាន ? ពីអ្នកណា ?

៥-តើការប្រើប្រាស់សេរីភាពអ្វីខ្លះដែលអ្នកខ្លាច សព្វថ្ងៃនេះ ? ខ្លាច ហេតុអ្វី ? មិនខ្លាច ហេតុអ្វី ?

៦-តើមានបញ្ហាចោទអ្វីខ្លះ និង មកពីអ្នកណា ដែលធ្វើឱ្យប៉ះពាល់ដល់អ្នក សព្វថ្ងៃនេះ ?

៧-ប្រសិនបើបញ្ហាណាមួយបណ្តាលមកពីរដ្ឋ/សង្គម ធ្វើឱ្យមានភាពអយុត្តិធម៌បំផុត ទាក់ទងទៅនឹងការរៀនសូត្ររបស់អ្នក ដែលអំពើនោះអ្នកបានដឹងច្បាស់ តើអ្នកនឹងសម្ងំស្ងៀម ឬ ធ្វើដូចម្តេច ឬ ដោះស្រាយតាមវិធីណាដែលអ្នកគិតធ្វើ ?

៨-ប្រសិនបើគេបញ្ចោរ ឬរបៀបជាទិញទឹកចិត្ត ឬ សូកប៉ាន់អ្នក ដោយការផ្តល់រង្វាន់អ្វីមួយ ដូចជាដើម្បីប្តូរនឹងសន្លឹកឆ្នោត តើអ្នកគិតដូម្តេច ?

★សំនួរ

តើត្រូវដោះស្រាយរបៀបណាឬក៏មិនត្រូវធ្វើ បើធ្វើតាមជំហានណាមុនគេ នូវគោលបំណងខាងក្រោមនេះ ដើម្បីឱ្យសម :

★ដោយមិនពេញចិត្តនឹងអំពើអយុត្តិធម៌របស់គ្រូ ឬនាយកសាលា ឬ ស្ថាប័នរដ្ឋ/សង្គម មកលើពួកគេសិស្សនិងនិស្សិតមួយក្រុមកំពុងគិតថា :

<u>**សំនួរបន្ទាប់**</u> :

1-ហេតុអ្វីបានជាត្រូវការសេរីភាពក្នុងការបញ្ចេញមតិ ?

2-តើការសំដែងមតិទាមទារបែបណាខ្លះ ដែលសន្តិភាព ?

3-តើការសំដែងមតិទាមទារណាមួយទៅដែលច្រើនតែមានដំណោះស្រាយល្អ ?

## VI.**អត្ថបទជំនួយ**

ដូចបានអធិប្បាយរួចមកហើយអំពីសេរីភាពក្នុងការបញ្ចេញមតិ មានន័យថា មិនមានអ្នកណាម្នាក់មកបំបិទមាត់យើងមិនឱ្យនិយាយបានឡើយ ។ ប្រសិនបើមានការរំលោភអ្វីមួយមកលើខ្លួនយើងឬសហគមន៍របស់យើង តើយើងត្រូវដោះស្រាយដោយរបៀបណា ?

### ១_វិធីដោះស្រាយបញ្ហា

★<u>**កំណត់បញ្ហាសំខាន់ៗ**</u> : ឧទាហរណ៍

-តើបញ្ហាសំខាន់ៗអ្វីខ្លះដែលបង្កការស្មុគស្មាញដល់ការសិក្សារបស់អ្នក ?

-តើអ្នកត្រូវធ្វើដូចម្តេចដើម្បីដោះស្រាយរឿងបងធំ ?

-តើបញ្ហាអ្វីខ្លះដែលធ្វើឱ្យរាំងស្ទះសិទ្ធិមានការងារធ្វើរបស់អ្នក នៅពេលបញ្ចប់ការសិក្សា ?

★**រៀបចំក្រុម ឬសមាគមសិស្ស-និស្សិត** និងមានតំណាងដឹកនាំសំរាប់ធ្វើការទំនាក់ទំនងឬសុំជួប

★កំនត់ក្រុមគោលដៅសំរាប់បកស្រាយឬជួយដោះស្រាយបញ្ហា

អ្នកដែលមានតួនាទីពាក់ព័ន្ធនឹងបញ្ហាខាងលើ ដូចជា : គ្រូបង្រៀនរបស់យើង នាយកសាលា មន្ទីរអប់រំខេត្ត-ក្រុង ក្រសួងអប់រំរហូតដល់ប្រមុខរដ្ឋាភិបាល ។ល។

★វិធីសំរាប់ធ្វើការបញ្ចុះបញ្ចូលដោះស្រាយបញ្ហា

មានពីរបែប :

1- **វិធីបញ្ចុះបញ្ចូលដោយផ្ទាល់** ដូចជា :

-ជាសំបុត្រផ្ញើជូន

-ការបង្កើតញត្តិដើម្បីឱ្យមានការគាំទ្រ

-ការចរចា សំរុះសំរួល

-ការសុំណាត់ជួប

-ការសុំជួបប្រជុំពិសេស ឬ

-ការជួបប្រជុំទល់មុខគ្នា (ជាមធ្យោបាយដ៏មានប្រសិទ្ធិភាព)

2-**វិធីបញ្ចុះបញ្ចូលដោយប្រយោល**

-ការដង្ហែជាក្បួនឬកូដកម្ម

-ការរៀបចំពិធីសិល្បៈផ្សព្វផ្សាយ

-ផ្សព្វផ្សាយតាមគ្រឿងផ្សាយពតិមាន កាសែត តាមខិតប័ណ្ណ , ផ្ទាំងរូបភាព....

យុទ្ធវិធីក្នុងការបញ្ចុះបញ្ចូល អាចកើតឡើងពីខ្សោយបំផុតរហូតដល់ខ្លាំងបំផុត ប្រសិនបើបញ្ហាឬសំណូមពរទាំងនោះ មិនត្រូវបានគេដោះស្រាយ ។

ដូច្នេះដើម្បីផ្លាស់ប្តូរស្ថានភាពអ្វីមួយឬមិនចង់ផ្លាស់ប្តូរ ត្រូវពាំនាំទស្សនៈយោបល់របស់អ្នក ទៅឱ្យចំមនុស្សដែលត្រូវបញ្ចុះបញ្ចូល ។

## ២_រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា៣៧:** សិទ្ធិធ្វើកូដកម្មនិង បាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តក្នុងក្របខណ្ឌនៃច្បាប់ ។

មាត្រា៤១: ប្រជាពលរដ្ឋខ្មែរមានសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។ របបសារពត៌មានត្រូវរៀបចំឡើងដោយច្បាប់ ។

មាត្រា៤២: ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និង គណៈបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយអាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។

ចប់

# លុបបំបាត់ការរើសអើងចំពោះស្ត្រីនិងទស្សនៈយេនឌ័រ

## I.ទស្សនៈ

ការរើសអើងគឺជាការប្រកាន់វណ្ណៈ ច្រាសមកវិញការប្រកាន់វណ្ណៈនាំឱ្យមានការរើសអើង ។ បញ្ហា



រើសអើងឬប្រកាន់វណ្ណៈ មានច្រើនសណ្ឋានទៅក្នុងសង្គមមនុស្ស ដូចជា រវាងអ្នកមាននិងអ្នកក្រ រវាងអ្នកធំនិងអ្នកតូច រវាងពូជសាសន៍និងពូជសាសន៍ ។ល។ ក៏ប៉ុន្តែមានបញ្ហារើសអើងដ៏ធំមួយរបស់សង្គម ហើយដែលមនុស្សភាគច្រើនកម្រនឹងយល់ឃើញ នោះគឺជាការរើសអើងរវាងបុរសនិងស្ត្រី ។ តើវាជាបញ្ហាពិតដូច្នេះមែនទេនៅក្នុងសង្គមខ្មែរយើងនោះ ?

សូមពិចារណាទៅលើចំណុចមួយក្នុងចំណោមចំណុចដទៃជាច្រើនទៀត នៃទម្លាប់របស់ខ្មែរដែលតែងតែគិតថាកូនស្រីមិនបាច់ឱ្យទៅរៀនសូត្រចេះដឹងវែងឆ្ងាយ ឬ ក៏ទៅធ្វើថីថុងអីដូចបុរសពេកទេ ចាំតែពឹងពាក់ប្តីទៅបានហើយ សំខាន់ឱ្យតែចេះកិច្ចការផ្ទះឬជាមេផ្ទះដ៏ល្អសំរាប់បំរើប្តីតាមក្បួនតម្រាស្រីទៅបានហើយ ។ ទម្លាប់នេះបានផ្តល់ឱ្យស្ត្រីភាគច្រើនចាំផ្ទះ និងមានមុខរបរធ្វើតែស្រែ-ចំការ-លក់ដូរ ហើយក្រៅពីកិច្ចការនេះមានបន្ទុកមើលថែទាំកូនផង ដាំ-ស្ងួផង ទុកដាក់ផ្ទះសម្បែងផង ។ល។ ដូច្នេះ លទ្ធផលជាមុខមាត់ក្នុងការចូលរួម ឬដឹកនាំដើម្បីជួយអភិវឌ្ឍន៍សង្គមនិងរកប្រាក់ចំណូលភាគច្រើនស្ថិតក្នុងកណ្តាប់ដៃបុរស ។ ទម្រង់ទាំងនេះក្លាយជាទម្លាប់របស់សង្គមឬជាអំនួតដែល



បង្ហាញ ឱ្យឃើញថា បុរសពោរពេញទៅដោយកម្លាំងពលំគ្រប់គ្រាន់ ។ ដូច្នេះផលប៉ះពាល់នាំឱ្យមានភាពបន្តុះបង្អាប់ មានការរើសអើងដល់ភេទមួយទៀត ដូចជាថាស្ត្រីទន់ខ្សោយ ស្ត្រីខ្វះភាពក្លាហាន និងមិន

អាចធ្វើអ្វីបានប្រសើរឡើយ ។ ដោយសារតែចំណុចទាំងនេះ បណ្តាលឱ្យស្ត្រីភាគច្រើនរងនូវអំពើទារុណកម្មពីប្តី ហើយមានខ្លះរហូតដល់ប្តីសម្លាប់ទៀតផង ។ ម្យ៉ាងវិញទៀតរហូតមកដល់បច្ចុប្បន្ននេះ ដោយសារតែទម្លាប់ក៏នៅតែធ្វើឱ្យស្ត្រីខ្លះខ្វះទំនុកចិត្តខ្លួនឯង និងមិនសូវមានជំនឿលើស្ត្រីដូចគ្នានៅឡើយសំរាប់តួនាទីផ្សេងៗ នៅក្នុងសង្គមក៏ដូចជាតួនាទីនៅក្នុងគ្រួសារដែរ ។

ទស្សនៈសិទ្ធិមនុស្សបានអះអាងថា ស្ត្រីនិងបុរសជាមនុស្សដូចគ្នា មានសិទ្ធិនិងសេចក្តីថ្លៃថ្នូរដូចៗគ្នាតាំងពីកំណើតគ្រាន់តែមានភេទផ្ទុយគ្នាប៉ុណ្ណោះ តើមកពីហេតុអ្វីបានជាធ្វើឱ្យមានវិសមភាពរវាងភេទទាំងពីរ ? តើវាអាចកែប្រែបានឬទេ ? កែប្រែដោយរបៀបណា ?




<u>**សំនួរ**</u> :

★ទស្សនៈនៃទំនៀមមួយបានលើកឡើងថា " ឪពុកម្តាយភាគច្រើន ស្រលាញ់កូនស្រីណាស់ មិនចង់ឱ្យចេញពីផ្ទះទៅណាឆ្ងាយដូចបុរសទេ ព្រោះគ្នាជាស្រីភេទទន់ខ្សោយ ហើយពេលមានប្តីសីទៅ បានប្តីចិញ្ចឹមហើយ ។

**ក/ទស្សនៈតាមទំនៀមទម្លាប់នេះ ផ្តល់ផលល្អដល់កូនស្រី ដូចម្តេចខ្លះ ? ហេតុអ្វី ?**

**ខ/ទស្សនៈនេះផ្តល់ផលអាក្រក់ដល់កូនស្រី ដូចម្តេចខ្លះ ? ហេតុអ្វី ?**

**ពិភាក្សាសំណួរខាងក្រោមនេះ**

1-ពិភាក្សាភាពដូចគ្នារវាងបុរសនិងស្ត្រី

2-ពិភាក្សាភាពខុសគ្នារវាងបុរសនិងស្ត្រី

3-រវាងបុរសនិងស្ត្រី ចំណុចដែលមិនអាចកែប្រែបាន និងចំណុចអាចកែប្រែបាន ហេតុអ្វី ?

4-អ្វីទៅដែលហៅថាភេទ ? និងអ្វីទៅដែលហៅថា យេនឌ័រ ?

1-រៀបរាប់កិច្ចការឬជាកាតព្វកិច្ចដែលបុរសត្រូវធ្វើ និងមិនត្រូវធ្វើ ហេតុអ្វី ។

2-រៀបរាប់កិច្ចការឬជាកាតព្វកិច្ចរបស់ស្ត្រីដែលត្រូវតែធ្វើ ហេតុអ្វី និង កិច្ចការណាដែលស្ត្រីមិនត្រូវធ្វើ ហេតុអ្វី ?

3-រវាងមុខការទាំងពីរ តើមានមុខការណាអាចផ្លាស់ប្តូរគ្នាបានទេ ? ហេតុអ្វី ?

4-អ្វីទៅហៅថាភេទ ?

1-បុរសភាគច្រើនតែងរកចំណូលចូលផ្ទះ ឯភរិយាគ្រាន់តែជាមេផ្ទះ តើការងារទាំងពីរ អ្នកណាសំខាន់ជាងអ្នកណា ? ហេតុអ្វី ?

2-រវាងមុខការអ្នកទាំងពីរដូចខាងលើវាអាចកែប្រែផ្លាស់ប្តូរបានឬទេ ? តើចំណុចណាខ្លះដែលត្រូវកែប្រែឱ្យប្រសើរនោះ (មិនមែនយកបុរសទៅដាំបាយរាល់ថ្ងៃនោះទេ) ជាពិសេសនាំឱ្យសង្គមគ្រួសារមានសេចក្តីសុខ និងនាំឱ្យគ្រួសារនីមួយៗកាន់តែមានជីវភាពធូរធារឡើងនោះ ?

3-អ្វីទៅដែលហៅថា យេនឌ័រ ?

1-តើមកពីមូលហេតុអ្វីបានជាស្ត្រីភាគច្រើនត្រូវបានទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ ? បង្ហាញហេតុផល ។ តើមានយុទ្ធសាស្ត្រអ្វីដើម្បីបញ្ឈប់នូវអំពើនេះ ?

2-ហេតុអ្វីបានជាមិនសូវមានស្ត្រីចូលរួមធ្វើការងារឬមានតួនាទីជាអ្នកដឹកនាំនៅក្នុងអង្គការរដ្ឋ និងសង្គម ? បង្ហាញហេតុផល ។ តើមានយុទ្ធសាស្ត្រអ្វីដើម្បីផ្តល់ឱ្យស្ត្រីចូលរួមក្នុងអង្គការរដ្ឋ ឬ អង្គការសង្គមឱ្យកាន់តែមានចំនួនច្រើនឡើងនោះ ?

**សំនួរបញ្ចប់**

1-តើអ្នកបានសិក្សាពីអ្វីខ្លះអំបាញ់មិញនេះ ?

2-តើវាជាការរើសអើងទៅលើស្ត្រី ពិត ឬ មិនពិត ? មកពីអ្វី ?

3-តើគួរជំរុញ-លើកទឹកចិត្តស្ត្រីឱ្យមានការចូលរួមក្នុងអង្គការរដ្ឋ/សង្គមឱ្យបានកាន់តែច្រើនឡើងៗ ឬទេ ? ហេតុអ្វី ?

## VI.**អត្ថបទជំនួយ**

### **១-ការយល់ដឹងពីយេនឌ័រ**

**១ក-អ្វីទៅដែលហៅថាភេទ** ? សំដៅលើភាពខុសគ្នាផ្នែកជីវសាស្ត្រ (ធម្មជាតិផ្តល់ឱ្យមានភេទប្រុស និងភេទស្រី មិនអាចផ្លាស់ប្តូរបាន) ។

**១ខ-អ្វីទៅដែលហៅថាយេនឌ័រ** ? វាមិនមែនជាកត្តាជីវសាស្ត្រទេ គឺសំដៅទៅលើភាពខុសប្លែកគ្នារវាងបុរសនិងស្ត្រីដែលត្រូវបានកំណត់ដោយសង្គម និងបានដឹងដោយខ្លួនឯងតាមរយៈសង្គម



និងមានការប្រែប្រួលពីពេលមួយទៅពេលមួយទៀត ។ យេនឌ័រអាចមានការផ្លាស់ប្តូរយ៉ាងទូលំទូលាយរវាងតួនាទីបុរសនិងស្ត្រីទៅតាមវប្បធម៌នៅក្នុងសង្គម និង រវាងវប្បធម៌មួយទៅវប្បធម៌មួយទៀត ។

យេនឌ័រគឺជាគោលគំនិតផ្នែកសេដ្ឋកិច្ចសង្គម ក្នុងការវិភាគលើតួនាទី ទំនួលខុសត្រូវ ឧបសគ្គ ឱកាស និងតម្រូវការរបស់បុរស-ស្ត្រីនៅគ្រប់បរិបទទាំងអស់ ។

## ១គ-គម្រូនការយេនឌ័រ

ការតម្រូវឱ្យមានយេនឌ័រគឺជាស្ថានភាពសុក្រិតដែលក្នុងនោះស្ត្រីនិងបុរសមានឱកាសស្មើគ្នា សិទ្ធិស្មើគ្នា អំណាចស្មើគ្នា ចែករំលែកការទទួលខុសត្រូវស្មើគ្នា មានតួនាទីស្មើគ្នា នៅក្នុងគ្រួសារ ក្នុងសង្គម និងនៅក្នុងសហគមន៍ ។

## ១ឃ-គោលដៅយេនឌ័រ

**ក/តម្រូវការយេនឌ័រជាក់ស្តែង :**

គឺជាការឆ្លើយតបមួយចំពោះសេចក្តីត្រូវការជាចាំបាច់ភ្លាមៗ និងជាបន្ទាន់សំរាប់ស្ត្រីដែលពាក់ពន្ធ័ទៅនឹងភាពមិនគ្រប់គ្រាន់នៅក្នុងស្ថានភាពរស់នៅ ការថែទាំសុខភាព និងការបំពេញការងាររបស់ពួកគេ ។





**ខ/តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ :**

គឺជាការផ្តល់ឱកាសឱ្យស្ត្រីទទួលបាននូវសមធម៌ និង សមភាពយេនឌ័រ ទាក់ទងទៅនឹងពលកម្ម ការងារ ការបែងចែកអំណាច តួនាទី នៅក្នុងគ្រួសារ ក្នុងរដ្ឋ និងក្នុងសង្គម ។

## ២.ច្បាប់ការពារសមភាពផ្នែកភេទ :

### ២ក/រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

**✦ មាត្រា៣៦ :** (កថាខណ្ឌ៣) ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

**✦ មាត្រា៤៥ :**

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ត្រូវលុបបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងារស្ត្រី ត្រូវហាមឃាត់ ។

បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍និងគ្រួសារ ។

អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ ។

**២៦/ច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជាសម័យអន្តរកាល :**

**+ មាត្រា៤១** : (អំពើបង្ករបួសដោយចេតនា) ជនណាវាយតប់បណ្តាលឱ្យមានរបួស ដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ឬពិការបណ្តោះអាសន្នរយៈពេលលើសពី៦ខែដោយចេតនា ត្រូវមានទោសពីបទបង្ករបួសស្នាមដោយចេតនា ហើយត្រូវផ្តន្ទាទោស ដាក់គុកពី១ឆ្នាំទៅ៥ឆ្នាំ ។

-បើពិការភាពបណ្តោះអាសន្នតិចជាង៦ខែ ត្រូវដាក់គុកជននោះពី៦ខែដល់២ឆ្នាំ ។

-បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទាដាក់គុកពី២ខែឡើងទៅ១ឆ្នាំ ។

-បើការវាយតប់នោះ ធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ ប្រភេទទោសត្រូវកំណត់១ជា២ ។

**២៧/កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស**

**+ មាត្រា៣ :** រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញាទាំងពីរនេះ ត្រូវធានាឱ្យមានភាពស្មើគ្នារវាងបុរសនិងស្ត្រីក្នុងការប្រើសិទ្ធិទាំងអស់ខាងផ្នែក សិទ្ធិពលរដ្ឋ-នយោបាយ និងសិទ្ធិសេដ្ឋកិច្ច-សង្គម និងវប្បធម៌ ។



**ចប់**

# សិទ្ធិអប្បភាគជន/ជនជាតិភាគតិច

## I. ឧស្សនៈ

នៅក្នុងប្រទេសណាក៏ដោយតែងតែមានជានិច្ច ការរស់នៅរបស់ពូជសាសន៍ ដូចជា : អន្តោគ្រាម (ជាម្ចាស់ស្រុកដើម), ជាតិពន្ធ (ជាតិសាសន៍ដទៃដែលបានរស់នៅតំណក្នុងប្រទេសណាមួយ) , អន្តោប្រវេសន៍ (ជនទាំងឡាយណាដែលមកសុំរស់នៅប្រទេសណាមួយក្រៅពីប្រទេសរបស់ខ្លួន) ឬ ជនភៀសខ្លួន (ជនសុំជ្រកកោនប្រទេសណាមួយដែលប្រទេសខ្លួនមានសង្គ្រាម ឬកើតភាពវឹកវរចលាចលអំពីអ្វីមួយ) ។



សំរាប់ប្រទេសកម្ពុជា ក៏មានការរស់នៅរបស់ក្រុមទាំងនេះ ដូចជាពួកអន្តោគ្រាមមាន ភ្នង គួយ ចារ៉ាយ ។ល។ និង ជាតិពន្ធ មាន ចាម ចិន វៀតណាម ជាដើម ។

សិទ្ធិមនុស្សបានចែងថា មនុស្សទាំងអស់មិនត្រូវបានគេបែងចែក ឱ្យខុស១ពីគ្នា ដោយប្រកាន់ទៅលើជាតិសាសន៍-ពណ៌ សម្បុរ-វណ្ណៈ-អ្នកមាន-អ្នកក្រ-ភាសា-សាសនា និង មតិនយោបាយអ្វីឡើយ ។ មានន័យថា មនុស្សទាំងអស់មិនថាមានភាគតិចឬភាគច្រើនទេ គឺត្រូវទទួលបាននូវសិទ្ធិនិងសេចក្តីថ្លៃថ្នូរដូច១គ្នាតាំងពីកំណើត ព្រមទាំងត្រូវទទួលបាននូវសិទ្ធិឱ្យគេទទួលស្គាល់ខ្លួនជាមនុស្សពេញលក្ខណៈច្បាប់ ទោះបីនៅទីកន្លែងណាក៏ដោយ ។

និយាយដោយឡែកមនុស្សមានសិទ្ធិចេញចូលប្រទេសណាមួយដើម្បីសុំជ្រកកោនស្របច្បាប់ ក្នុងនាមជាអន្តោប្រវេសន៍ ជាជនភៀសខ្លួនឬធ្វើទស្សនកិច្ច/ កំសាន្ត ជាដើម ។ល។



(ការិយាល័យអន្តោប្រវេសន៍)

ការចេញចូលរបស់ជនបរទេសមកក្នុងប្រទេសណាមួយ វាជាអំណាចឬជាកាតព្វកិច្ចរបស់រដ្ឋាភិបាលប្រទេសនោះដែលត្រូវតែគ្រប់គ្រងឱ្យបាននិងស្របតាមច្បាប់ ផ្ទុយទៅវិញបើពួកគេបានចូលមករស់នៅហើយ ពួកគេក៏មានសិទ្ធិមនុស្សដូចជាអ្នកនៅក្នុងស្រុកដែរ លើកលែងតែករណីខ្លះទាក់ទងទៅនឹងសិទ្ធិបោះឆ្នោត សិទ្ធិនេះលុះត្រាតែគេត្រូវបានទទួលឱ្យចូលសញ្ជាតិសិនតាមក្របខណ្ឌនៃច្បាប់ ។ ម្យ៉ាងវិញទៀត ពួកគេក៏មិនត្រូវទទួលរងនូវការរំលោភដល់ផ្លូវកាយ-ចិត្ត ប្រសិនបើពួកគេមានកំហុសឬក៏ត្រូវបិទសិទ្ធិសេរីភាពអ្វីនោះឡើយ តែពួកគេក៏ត្រូវទទួលការអប់រំអំពីសិទ្ធិរស់នៅក៏ដូចជាធ្វើឱ្យចេះគោរពសិទ្ធិអ្នកដទៃផងដែរ ។

ដូច្នេះក្នុងនាមម្ចាស់ស្រុក គួរមានការយោគយល់-អត់ឱន/មិនប្រើអំពើហិង្សាដល់ជនជាតិភាគតិចទាំងនោះទោះបីពួកគេ ជាជាតិពន្ធ ជាអន្តោប្រវេសន៍យ៉ាងណាក៏ដោយ ពួកគេត្រូវតែទទួលបាននូវសិទ្ធិផ្សេងៗ ដូចជាសិទ្ធិចូលរួមក្នុងជីវភាពសង្គម ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស សិទ្ធិបង្កើតនិងរក្សាសមាគម សិទ្ធិទាក់ទងដោយសេរីនិងសន្តិវិធីជាមួយសមាជិក និងក្រុមគ្រួសាររបស់គេ ជាពិសេសសិទ្ធិសំខាន់ៗបីរបស់ពួកគេដូចជា សិទ្ធិរៀនសូត្រភាសា ប្រពៃណី ប្រវត្តិសាស្ត្រ និងវប្បធម៌របស់ពួកគេ ។ អំពើប្រឆាំងណាមួយជាចំហឬសម្ងាត់ ឬរើសអើងទៅលើពួកទាំងនេះ គឺជាការរំលោភសិទ្ធិមនុស្ស និងនាំឱ្យមានអស្ថិរភាពក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម វប្បធម៌ និងនយោបាយ ឬក៏នាំឱ្យប្រទេសជាតិដើរថយក្រោយ ។

★ **<u>សំនួរ</u>:**

**1-តើអ្វីខ្លះជាគំនិតសំខាន់ៗនៅក្នុងអត្ថបទនេះ ?**

**2-តើនៅក្នុងភូមិ/ឃុំរបស់អ្នក មានជនជាតិភាគតិចរស់នៅឬទេ ? (ជាអន្តោគ្រាម ជាតិពន្ធ អន្តោប្រវេសន៍/ជនភៀសខ្លួន) ។**

**3-តើពួកគេធ្លាប់បានទទួលរងឬធ្វើទុក្ខបុកម្នេញ ពីអ្នកណា ដែរឬទេ ? ដូចម្តេចខ្លះ ? មកពីហេតុអ្វី ?**

## ករណីសិក្សា

ក្នុងភូមិរបស់អ្នក សម្បូរទៅដោយជនជាតិចាមនិងវៀតណាម ជាពិសេសផ្ទះរបស់អ្នកនៅជាប់នឹងតៀមកាហ្វេវៀតណាម ដែលស្ទើរជាទូទៅគេដឹងថា ទូរទស្សន៍របស់គេបើកតែចម្រៀងឬក៏ព្រឹត្តិការណ៍ផ្សេងៗនៅតែក្នុងប្រទេសរបស់គេតែប៉ុណ្ណោះ ។ ចំណែកឯជនជាតិចាមវិញ គេឮសូត្រតែសូត្រធម៌ព្រះរបស់គេជារៀងរាល់ពេល ដោយមានប្រើមីក្រូទៀតផង ។ ឪពុករបស់អ្នកនិងអ្នកជិតខាងមួយចំនួនបានជជែកគ្នាថា បើបណ្តោយឱ្យពួកគេធ្វើយ៉ាងនេះ វាប៉ះពាល់ខ្លាំងណាស់ដល់វប្បធម៌ជាតិយើង ហើយប្រៀបបីដូចប្រទេសយើងគ្មានច្បាប់ បណ្តោយឱ្យគេធ្វើអីស្រេចនឹងចិត្តយ៉ាងនេះ ។ ក្នុងចំណោមនោះមានម្នាក់និយាយថា ពួកយួនទាំងនេះប្រហែលចូលមករស់នៅមិនស្របច្បាប់ទៀតផង ។ ពេលកំពុងតែជជែកគ្នានោះគេឮសូរវ៉ៃក្លុងក្លាំង និងសម្លេងស្រែកយំទ្រហឹងនៅក្នុងតៀមកាហ្វេវៀតណាមនោះ ឪពុកអ្នកបានប្រាប់អ្នកទាំងនោះថា វាឈ្លោះវ៉ៃប្រពន្ធវាស្ទើរតែរាល់យប់ហ្នឹងឯង ថ្ងៃមុននោះឃើញបែកក្បាលហូរឈាមម្តងហើយ មានម្នាក់បានបន្ទរថា ឱ្យវាវ៉ៃឱ្យងាប់ទៅចុះកុំទៅឈឺក្បាលហាលថ្ងៃ បើខ្មែរយើងវិញចេះតែនាំគ្នាជួយឃាត់ទៅ! តែពួកវាមកនៅស្រុកយើងហើយបង្ករឿងទៀត បើស្រួលបានតែដំបងព្រនង់ដេញឱ្យវាទៅស្រុកវាវិញ រំពេចនោះមានម្នាក់ទៀតនិយាយថា ឥឡូវចាមតម្លង់រាល់តែយប់ហើយកើតវិហារកាន់តែច្រើន ចំណែកយេស៊ូក៏ដូចតែគ្នា ស្លាប់ហើយស្រុកយើង ។

### ★សំនួរ

១-តើជនជាតិចាម/វៀតណាមទាំងនោះមានទង្វើ/សកម្មភាពអ្វីខ្លះនៅក្នុងភូមិរបស់អ្នក ?

២-តើជនជាតិចាម/វៀតណាមទាំងនោះបានធ្វើអ្វីខ្លះឱ្យរំខាន/ប៉ះពាល់ដល់ភូមិរបស់អ្នក ?

៣-ចូរស្រង់សំដីត្រង់ណាខ្លះ ដែលជាសំដីតបត-ខឹងសម្បារពីឪពុកអ្នកនិងអ្នកជិតខាង ?

៤-ចំពោះអ្នកវិញ តើអ្នកយល់យ៉ាងដូចម្តេច ចំពោះទង្វើ/សកម្មភាពរបស់ចាម-វៀតណាមនៅក្នុងភូមិរបស់អ្នក ? យោបល់

៥-តើអ្នកយល់ដូចម្តេចចំពោះសំដីរិះគន់ខឹងសម្បាររបស់ឪពុកអ្នកនិងអ្នកជិតខាង ? តើចាត់ទុកជាសំដីយ៉ាងដូចម្តេច ?

៦-តើអ្នកមានយោបល់ដូចម្ដេចឬក៏យល់ស្របដូចអ្នកជិតខាងរបស់អ្នក ចំពោះអំពើហិង្សានៅក្នុងគ្រួសារវៀតណាមនោះ ?

៧-តើអ្នកយល់ព្រមឬទេដែលថា ជនជាតិភាគតិចមានសិទ្ធិមនុស្ស ? ហេតុអ្វី ?

៨-តើអ្នកមានវិធី/យោបល់យ៉ាងដូចម្ដេចខ្លះ ដើម្បីបំបាត់ការរើសអើង ឬ ធ្វើឱ្យមានការទទួលស្គាល់សិទ្ធិមនុស្សរបស់ជនជាតិភាគតិច ?

៩-តើជនអន្តោប្រវេសន៍របៀបណាដែលត្រូវផ្ដន្ទាទោស ? អ្នកណាមានតួនាទីក្នុងរឿងនេះ ?

១០-មានលក្ខខណ្ឌអ្វីខ្លះដែលអាចឱ្យជនបរទេសចូលសញ្ជាតិបាន ?

**<u>សំណួរ</u>**

1-តើអ្នកបានសិក្សាពីអ្វីខ្លះ អំបាញ់មិញ ?

2-បើសិនជាមានជនអន្តោប្រវេសន៍ខុសច្បាប់ត្រូវបានដោះស្រាយដោយអ្នកណា ? ធ្វើដូចម្ដេច ?

## VI. ច្បាប់ពាក់ព័ន្ធ

### ១-<u>សេចក្ដីថ្លែងការណ៍ជាសាកលស្ដីអំពីសិទ្ធិមនុស្ស</u>

**<u>មាត្រា២</u>** : មនុស្សទាំងអស់មិនត្រូវបានគេបែងចែកឱ្យខុសៗពីគ្នា ដោយប្រកាន់ទៅលើជាតិសាសន៍ ពណ៌សម្បុរ វណ្ណៈ អ្នកមាន ឬអ្នកក្រ ភាសា សាសនា មតិនយោបាយ ជាដើមឡើយ ។

### ២-ច្បាប់អន្តោប្រវេសន៍របស់ប្រទេសកម្ពុជា

**<u>មាត្រា២</u>** : ត្រូវចាត់ទុកជាជនបរទេស ជនណាដែលគ្មានសញ្ជាតិជាខ្មែរ ដោយគ្មានរើសអើង ទោះបីជននោះមានសញ្ជាតិ ជំនឿសាសនា ឬមានដើមកំណើតណាមួយក៏ដោយ ។

**<u>មាត្រា៥</u>** : ការគ្រប់គ្រងជនបរទេសជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។ ក្រសួងនេះត្រូវមានស្ថាប័នមួយ ដើម្បីទទួលកិច្ចការអន្តោប្រវេសន៍ ។

**មាត្រា២៩** : ជនបរទេសណាដែលគ្មានការអនុញ្ញាត ហើយចូលមករស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយលបលាក់បន្លំ ឬដោយល្បិចផ្សេងទៀតផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់គុក ពី ៣ខែដល់ ៦ខែ មុននឹងត្រូវបណ្តេញចេញ ។

**មាត្រា៣៧** : រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា រាល់ជនបរទេសណាដែលចូលក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ។

## ៣-ច្បាប់សញ្ជាតិ :

**មាត្រា៨** : ជនបរទេសដែលអាចសុំសញ្ជាតិតូបនិយកម្មបាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ :

1-មានលិខិតបញ្ជាក់ថាមានគំនិតមារយាទនិងសីលធម៌ល្អដែលចេញដោយមេឃុំ ឬចៅសង្កាត់នៃទីលំនៅរបស់ខ្លួន ។

2-មានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលមានទោសពីបទព្រហ្មទណ្ឌណាមួយ ។

3-មានលិខិតបញ្ជាក់ថា ជននោះមានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់ចំនួន **ប្រាំពីរឆ្នាំ** ដោយគិតពីថ្ងៃដែលបានទទួលប័ណ្ណស្នាក់នៅ ដែលចេញឱ្យក្នុងក្របខណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ។

4-មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដាក់ពាក្យសុំសញ្ជាតិតូបនិយកម្ម ។

5-ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាងច្បាស់ថា ខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលបាននូវទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ខ្មែរ ។

6-មានបញ្ញានិងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ឬនាំឱ្យមានបន្ទុកដល់ជាតិ ។

**ចប់**

# ការបង្កើតយុទ្ធសាស្ត្រសំរាប់ការពារ

I. **ទស្សនៈ:** យុវជន/យុវនារីប្រៀបបាននឹងទំពាំងស្នងឬស្សី និងជាវ័យដ៏ពិសេស សំរាប់ជាសសរទ្រូងរបស់ប្រទេសជាតិ ។ យ៉ាងណាមិញ! ដើម្បីធ្វើឱ្យប្រទេសជាតិមានការរីកចំរើន ឬក៏ធ្វើឱ្យមានការផ្លាស់ប្តូរអ្វីមួយសំដៅទៅរកភាពត្រឹមត្រូវ យុត្តិធម៌/ភាពដែលអាចទទួលយកបាន និងមានតម្លាភាពនោះ គឺមានតែអ្នកនេះហើយដែលជាកម្លាំងចលករដ៏សំខាន់ និង ស្រួចស្រាវបំផុតនោះ ។ ឥឡូវនេះអ្នកកំពុងត្រូវបានលើកស្ទួយនិងកំពុងក្តាប់យ៉ាងណែនន្ទូវអ្វីដែលជាសិទ្ធិរបស់អ្នក ពិសេសប្រជាធិបតេយ្យរបស់អ្នក ដែលត្រូវបានការពារយ៉ាងជាក់លាក់ដោយច្បាប់ប្រទេសកម្ពុជា ។ ដូច្នេះ ដើម្បីការពារនិងលើកស្ទួយសិទ្ធិមនុស្សបាន លុះត្រាតែមនុស្សទាំងអស់ជាពិសេសរូបអ្នកចូលរួមសកម្មភាពអនុវត្តសិទ្ធិមនុស្សទៅតាមវិធីច្រើនបែបច្រើនយ៉ាង សំរាប់ធ្វើឱ្យមានការកែប្រែអ្វីមួយសំរាប់រូបអ្នក សំរាប់សហគមន៍ក៏ដូចជាសង្គមជាតិទាំងមូលរបស់អ្នកផងដែរ ។

**យុទ្ធសាស្ត្រជាមូលដ្ឋានដ៏រឹងមាំ**មួយសំរាប់ជាគ្រឹះការពារសិទ្ធិមនុស្ស គឺជាការ**បង្កើតក្រុមការពារសិទ្ធិមនុស្សស្ម័គ្រចិត្តដែលមានយុវជន/នារីចូលរួម និង ចងក្រងជាបណ្តាញ** សំរាប់សហការជាមួយក្រុមដទៃទៀត មានក្រុមប៉ូលីស ក្រុមប្រជាពលរដ្ឋ ជាពិសេសជាមួយអង្គការក្រៅរដ្ឋាភិបាលនានា ក្នុងគោលបំណងជួយបន្តការអប់រំសិទ្ធិមនុស្សដល់អ្នកដទៃ ឬ ជួយទប់ទល់ទៅលើស្ថានភាពរំលោភសិទ្ធិមនុស្សដូចជាការផ្តល់ពត៌មានអំពីករណីរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ជួយឈឺឆ្អាលដោះស្រាយកិច្ចការសិទ្ធិមនុស្សតូចតាចដែលអាចធ្វើទៅបាន ជាពិសេស <u>ធ្វើការតស៊ូមតិ</u>[1] តាមវិធីច្រើនបែបច្រើនយ៉ាង ដូចជាការបញ្ចុះបញ្ចូលដោយផ្ទាល់ឬដោយប្រយោលទៅក្នុងចំណោមបុគ្គលដែលមានអំណាចណាមួយពាក់ព័ន្ធនឹងរឿងរបស់អ្នក ឬសហគមន៍របស់អ្នក ដើម្បីទាមទារឱ្យមានការកែប្រែអ្វីមួយសំដៅទៅរកភាពត្រឹមត្រូវ យុត្តិធម៌ និង តម្លាភាព ដូចបានពោលខាងលើ ។

តើអ្វីខ្លះជាគំនិតសំខាន់ៗនៅក្នុងអត្ថបទនេះ ?

---

[1] មើលក្នុងអត្ថបទការលើកដែងមតិនិងវិធីទាក់ទាញការគាំទ្រ

★ **សំនួរ**

1-ការរំលោភ-បំពានសិទ្ធិមនុស្សរួមទាំងអ្នកផងពីអ្នកមានអំណាច មានច្រើនបែបច្រើនយ៉ាងណាស់ ដូច្នេះដើម្បីកាត់បន្ថយ លុបបំបាត់អំពើទាំងនោះ តើវាត្រូវបានដោះស្រាយដោយមនុស្សតែ២-៣នាក់ ឬត្រូវការចូលរួមដោយមនុស្សភាគច្រើន ? ហេតុអ្វី ?

2-យោងតាមទស្សនៈខាងលើនេះ តើគេចង់រៀបចំអ្វីមុនគេ ដែលជាយុទ្ធសាស្ត្រចម្បងសំរាប់ការការពារសិទ្ធិមនុស្សនោះ ? និង

3-យោងតាមទស្សនៈនេះដែរ តើគេចង់ធ្វើអ្វីខ្លះទៀត ដែលជាយុទ្ធសាស្ត្រសំខាន់ៗសំរាប់ការពារសិទ្ធិមនុស្សបន្ថែមទៀតនោះ ?

4-ក្នុងនាមអ្នកជាពលរដ្ឋខ្មែរមួយរូប តើអ្នកគួរស្ម័គ្រចិត្តចូលរួមការពារសិទ្ធិមនុស្សឬទេ ? ជួយតាមវិធីណាខ្លះដែលអាចធ្វើទៅបាន និងរៀបចំទ្រង់ទ្រាយដូចម្ដេច ដើម្បីកាត់បន្ថយការរំលោភសិទ្ធិមនុស្សឱ្យមានប្រសិទ្ធិភាព ?

★ អ្វីខ្លះដែលជាករណីរំលោភសិទ្ធិមនុស្ស ?

ករណីទាំងនោះមានដូចជា អំពើហិង្សាក្នុងគ្រួសារ ការសម្លាប់ដោយហ្វូងមនុស្សហិង្សា



ការចាប់និងការឃុំខ្លួនខុសច្បាប់ ការធ្វើទារុណកម្មទៅលើជនដែល គេចាប់ខ្លួននិងឃុំខ្លួន ឃាតកម្ម (ការសម្លាប់មនុស្សដោយលួចលាក់និងចំហ ) ការគំរាមកំហែង ទៅលើសកម្មជននយោបាយ ឬ អ្នកគាំទ្រនយោបាយ ការចាប់ជំរិត អ្នកលក់ថ្នាំញៀន ការរំលោភដីធ្លីពីអាជ្ញាធរ ដោយផ្ទាល់ ដោយប្រយោល ឬការគាំទ្រពីក្រោយខ្នងរបស់ អាជ្ញាធរចំពោះពលរដ្ឋ ស៊ីវិលណាមួយ ។ ក្នុងចំណោមករណីខាងលើនេះប្រសិនបើមាន ក្រុមការងារនឹងអាចដោះស្រាយតាមលទ្ធភាពដែលខ្លួនអាចធ្វើ ឬយ៉ាងហោចណាស់ក៏ត្រូវផ្តល់ពត៌មានពីករណីខាងលើដល់អង្គការជាដៃគូឱ្យបានឆាប់ដែលអាចធ្វើទៅបាន ។

## ទម្រង់របាយការណ៍សង្ខេប

**១.ឈ្មោះករណីរំលោភ......................................**

**២.ជនរងគ្រោះ :**

ឈ្មោះ..........................ភេទ.............អាយុ..............មុខរបរ......................................

ទីលំនៅ : ភូមិ......................ឃុំ/សង្កាត់.............................ស្រុក/ខណ្ឌ........................

ខេត្ត/ក្រុង.......................................

ទីកន្លែងកើតហេតុ : ភូមិ....................ឃុំ/សង្កាត់.......................ស្រុក/ខណ្ឌ....................

ពេលវេលា : នៅម៉ោង.............ថ្ងៃទី........ខែ..............ឆ្នាំ ២០០...

**៣.អ្នកប្រព្រឹត្ត**

ឈ្មោះ......................ភេទ............អាយុ................មុខរបរ................................

ទីលំនៅ : ភូមិ..................ឃុំ/សង្កាត់.........................ស្រុក/ខណ្ឌ.......................

ខេត្ត/ក្រុង................................

ពេលវេលា : នៅម៉ោង................ថ្ងៃទី...........ខែ................ឆ្នាំ២០០...

**៤.ឧបករណ៍រំលោភទៅលើជនរងគ្រោះ**

..........................................................................................................................................

..........................................................................................................................................

៥.មូលហេតុបណ្តាលឱ្យកើតរឿងនេះ

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៦.អ្នកបានធ្វើអ្វីខ្លះមុនបញ្ជូនរឿងនេះមក ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

ធ្វើនៅថ្ងៃទី.......ខែ..........ឆ្នាំ២០០...

អ្នករាយការណ៍

ហត្ថលេខា...................

ឈ្មោះ........................

**★សំនួរ**

តើគំនិតសំខាន់ៗនៅក្នុងអត្ថបទនេះ ចង់បានសំណួមពរអ្វីពីអ្នក?

## VI.ច្បាប់របស់ប្រទេសកម្ពុជា

### ១-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៣២ : ជនរាល់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

មាត្រា៤២ : ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។ ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធិផល ជាតិនិងសណ្តាប់ធ្នាប់សង្គម ។

## ២-ច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជាសម័យអន្តរកាល :

មាត្រា៣២ : ជនណាដែលសម្លាប់មនុស្សដោយចេតនា ដោយបានប្រើឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋ ពី៨ឆ្នាំ ទៅ ១៥ឆ្នាំ ។

មាត្រា៣៣ : ជនណាក៏ដោយដែលរំលោភសេពសន្ថវៈលើជនណាម្នាក់ទៀត ទោះភេទដូចគ្នាឬមិនដូចគ្នាយ៉ាងណាក៏ដោយ ត្រូវមានទោសពីបទរំលោភសេពសន្ថវៈ ហើយត្រូវផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋពី៥ឆ្នាំទៅ១០ឆ្នាំ ។

មាត្រា៣៤ : (អំពើប្លន់) ការលួច ធ្វើដោយអំពើហិង្សា មានអាវុធឬឥតអាវុធ បណ្តាល ឬមិនបណ្តាលឱ្យមានរបួស ត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្តន្ទាទោសដាក់គុកពី៣ឆ្នាំ ទៅ១០ឆ្នាំ ។

មាត្រា៤០ : (អំពើមនុស្សឃាតដោយអចេតនា) ជនណា ដោយខ្វះការប្រុងប្រយ័ត្ន ដោយការធ្វេសប្រហែសមិនប្រុងប្រយ័ត្ន ឬមិនបានគោរពតាមបទបញ្ជាធ្វើឱ្យស្លាប់ជនម្នាក់ទៀតដោយអចេតនា ត្រូវមានទោសពីបទមជ្ឈិមធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី១ឆ្នាំទៅ៣ឆ្នាំ ។

មាត្រា៤១ : (អំពើបង្ករបួសដោយចេតនា ) ជនណាវាយតប់បណ្តាលឱ្យមានរបួសដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ ឬពិការបណ្តោះអាសន្នក្នុងរយៈពេលលើសពី៦ខែដោយចេតនា ត្រូវមានទោសពីបទបង្ករបួសដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់គុកពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

-បើពិការភាពបណ្តោះអាសន្នតិចជាង៦ខែ ត្រូវផ្តន្ទាទោសដាក់គុកជនទោះពី៦ខែដល់២ឆ្នាំ ។

-បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទា គឺដាក់គុកពី១ខែដល់១ឆ្នាំ ។

-បើការវាយតប់នោះធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ កំរិតទោសត្រូវទ្វេមួយជាពីរ ។

## ៣-ច្បាប់ស្តីពីការបង្ក្រាបអំពើចាប់ជំរិត អំពើលក់ដូរ និង អំពើអាជីវកម្មលើមនុស្ស

មាត្រា៣ : ជនណាអូសទាញមនុស្ស ទោះស្រីឬប្រុស អនីតិជនឬនីតិជនមានសញ្ជាតិអ្វីក៏ដោយ ដោយវិធីលួងលោម សន្យាឱ្យប្រាក់កាស ឬគ្រឿងអលង្ការ ឬតាមវិធីណាក៏ដោយ ទោះសាមីខ្លួនសុខចិត្តឬមិនសុខចិត្ត ដោយវិធីបង្ខិតបង្ខំគំរាមកំហែង ឬប្រើថ្នាំសណ្តំស្មារតីនិងសតិអារម្មណ៍ ដើម្បីពង្រត់យកមកលក់ឬយក ទៅធ្វើពេស្យាចារ ជននោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំ ដល់ ១៥ឆ្នាំ ។

**ចប់**

## សម្ព័ន្ធខ្មែរជំរឿន និង ការពារសិទ្ធិមនុស្ស ដែលហៅកាត់ថា លីកាដូ

គឺជាអង្គការដែលមិនមែនរដ្ឋាភិបាល មិនរកផលកម្រៃ ហើយមិនមែនជាគណបក្សនយោបាយឡើយ ។ អង្គការនេះមានគោលដៅលើកស្ទួយសិទ្ធិមនុស្ស ព្រមទាំងការពារប្រជាពលរដ្ឋនូវអំពើរំលោភសិទ្ធិមនុស្ស ។

ចំណែកពត៌មានផ្សេងៗ សូមអញ្ជើញមកទាក់ទងនៅការិយាល័យលីកាដូ តាមបណ្តាខេត្តទាំង១២ ឬ រាជធានីភ្នំពេញ ស្ថិតនៅផ្ទះលេខ ១០៣ ផ្លូវលេខ ៩៧ ខណ្ឌចំការមន ក្រុងភ្នំពេញ ។


សូមទំនាក់ទំនង ទូរស័ព្ទ : (០២៣) ៣៦០ ៩៦៥ / ៣៦៤ ៩០១

ទូរសារ : (០២៣) ៣៦០ ៩៦៥ / ២១៧ ៦២៦

អ៊ីមែល : licadho@camnet.com.kh

ប្រធាន : លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក


**The Cambodian League for the Promotion and Defense of Human Rights (LICADHO) is a non-goverr mental, non-profit, apolitical organization, working to promote human rights and protect the population from human rights violations.**

**For further information, please contact LICADHO in 12 provinces or in Phnom Pen at:**


**# 103, Street 97, Khan Chamcar Mon, Phnom Penh**

**Phone:** (023) 360 965 / 364 901

**Fax:** (023) 360 965 / 217 626

**E-mail:** licadho@camnet.com.kh

**President: Dr. PUNG CHHIV KEK**

លីកាដូ

LICADHO

បោះពុម្ពផ្សាយដោយ លីកាដូ
PUBLISHED BY
LICADHO

ឧបត្ថម្ភថវិការបស់ ដានីដា
FUNDED BY
DANIDA

# មិនលក់
# NOT FOR SALE

រក្សាសិទ្ធិដោយអង្គការលីកាដូ
Copyright by LICADHO

បោះពុម្ព លើក ទី ២ ចំនួន ៧០០ ក្បាល
ខែ មេសា ឆ្នាំ ២០០៤